GMAC
Garment Manufacturers Association in Cambodia

# សេចក្តីប្រកាសព័ត៌មានស្តីពីភាពជាដៃគូ

រាជធានីភ្នំពេញ ថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៨: សមាគមរោងចក្រកាត់ដេរនៅកម្ពុជា(GMAC) និងក្រុមហ៊ុន FUNAN Consulting Co.មានសេចក្តីរីករាយសូមប្រកាសនៅថ្ងៃនេះអំពីភាពជាដៃគូធ្វើការងារជាផ្លូវការរបស់យើង ក្នុងគោលបំណងពង្រឹងសមត្ថភាពសមាជិកទាំងអស់របស់សមាគមនៅក្នុងវិស័យអនុលោមភាពពន្ធដារ និងការអនុវត្ត។

ភាពជាដៃគូធ្វើការងារជាផ្លូវនេះបានឈានដល់ការព្រមព្រៀងគ្នានាពេលថ្មីៗនេះតាមរយៈអនុស្សរណៈនៃការយោគយល់គ្នា(MoU) ដែលក្នុងនោះក្រុមហ៊ុន FUNAN ប្តេជ្ញាចិត្តផ្តល់សេវាប្រឹក្សាយោបល់អំពីបញ្ហាពាក់ព័ន្ធនឹងពន្ធដារ និងសេវាបណ្តុះបណ្តាលពន្ធដារ ព្រមទាំងសិក្ខាសាលានិងវេទិកាស្តីពីពន្ធដារដែលមានលក្ខណៈទូលំទូលាយជាងមុនទៅដល់បណ្តារោងចក្រនាំចេញទាំងអស់ដែលជាសមាជិករបស់សមាគម។

ក្រោមកិច្ចព្រមព្រៀងគ្នានេះ ភាគីទាំងពីរបានព្រមព្រៀងគ្នាថា យើងនឹងសហការជិតស្និទ្ធនិងប្រឹក្សាយោបល់គ្នាទៅវិញទៅមកលើបញ្ហាអត្ថប្រយោជន៍ទៅវិញទៅមក ដើម្បីនាំមកនូវអនុលោមភាពពន្ធដារប្រសើរជាងមុននិងបរិយាកាសអនុវត្តប្រសើរជាងមុននៅក្នុងឧស្សាហកម្មកាត់ដេរសម្លៀកបំពាក់និងស្បែកជើង។

លោក កាំង ម៉ូនីកា អគ្គលេខាធិការរងនៃសមាគមរោងចក្រកាត់ដេរនៅកម្ពុជា បានថ្លែងថា នេះគឺជាការឈានទៅរកទិសដៅត្រឹមត្រូវមួយ ដោយសារពន្ធដារត្រូវបានកំណត់ជាបញ្ហាមួយក្នុងចំណោមបញ្ហាអាទិភាពនៅក្នុងឧស្សាហកម្មកាត់ដេរសម្លៀកបំពាក់ និងស្បែកជើងរបស់យើងដែលកំពុងជួបបញ្ហាប្រឈម។ ច្បាស់ណាស់ សមាជិករបស់យើងនឹងទទួលបានអត្ថប្រយោជន៍ពីសេវាតម្លៃបន្ថែមនេះ។ អនុស្សរណៈនៃការយោគយល់គ្នា(MoU) បង្កើតនូវក្របខ័ណ្ឌសម្រាប់កិច្ចសហការរវាងដៃគូ ហើយយើងបានព្រមព្រៀងគ្នាថា MoU មិនមានឥទ្ធិពលទៅលើសកម្មភាពផ្សេងៗដែលមិនមានចែងនៅក្នុង MoU នេះ ហើយយើងអាចធ្វើការសហការលើសកម្មភាពស្រដៀងគ្នានេះជាមួយដៃគូដទៃៗបានផងដែរ។

ក្រុមហ៊ុនប្រឹក្សាយោបល់ FUNAN Consulting គឺជាក្រុមហ៊ុនមួយក្នុងចំណោមក្រុមហ៊ុនដែលរីកចម្រើនយ៉ាងលឿនបំផុតដែលមានក្រុមគណនេយ្យករនិងក្រុមពន្ធដារប្រកបដោយវិជ្ជាជីវៈនិងជំនាញ



តំបន់សេដ្ឋកិច្ចពិសេសភ្នំពេញ ភូមិត្រពាំងគល់ សង្កាត់កន្ទោក ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
Phnom Penh Special Economic Zone, Trapeang Kul Village, Sangkat Kantouk, Khan Por Sen Chey, Phnom Penh Cambodia.
Tel: (855) 23-88 34 35 E-mail: info@gmac-cambodia.org Website: www.gmac-cambodia.org

បទពិសោធន៍ ការទទួលស្គាល់ និងមានសមត្ថភាពផ្តល់សវនកម្មប្រកបដោយគុណភាពខ្ពស់និងសេវាជានា គណនេយ្យ ពន្ធដារ ការគ្រប់គ្រងហិរញ្ញវត្ថុ ការបណ្តុះបណ្តាល និងដំណោះស្រាយ IT។

លោក SENAKA Fernando អគ្គនាយក/ប្រធានក្រុមហ៊ុន FUNAN បានថ្លែងថា អនុស្សរណៈនៃការយោគយល់គ្នាបង្កើតឱកាសថ្មីមួយសម្រាប់ក្រុមហ៊ុន FUNAN ពង្រីកការងាររបស់ខ្លួនទៅក្នុងឧស្សាហកម្មកាត់ដេរសម្លៀកបំពាក់និងស្បែកជើង និងជួយសមាជិករបស់សមាគមដើម្បីយល់ដឹងបន្ថែមទៀតអំពីច្បាប់របស់កម្ពុជា បញ្ហាពន្ធដារ និងស្តង់ដារគណនេយ្យ ដែលពួកគេត្រូវតែគោរព។ យើងមានសេចក្តីរីករាយក្នុងការធ្វើការងារជាមួយសមាគមក្នុងការផ្តល់សេវាប្រឹក្សារបស់យើងដល់សមាជិកទាំងអស់របស់សមាគមទៅតាមសំណើ។ អនុស្សរណៈនេះនឹងដើរតួនាទីយ៉ាងសំខាន់ក្នុងការរួមចំណែកដល់ការកសាងធនធានមនុស្សនៅក្នុងឧស្សាហកម្មនេះ។

--------ចប់------------

អំពីសមាគមរោងចក្រកាត់ដេរនៅកម្ពុជា(GMAC)៖

សមាគមរោងចក្រកាត់ដេរនៅកម្ពុជាត្រូវបានបង្កើតឡើងតាំងពីឆ្នាំ១៩៩៦ ជាអ្នកតំណាងឧស្សាហកម្មកាត់ដេរសម្លៀកបំពាក់និងស្បែកជើងក្នុងការដោះស្រាយបញ្ហាទាំងអស់ដែលប៉ះពាល់ដល់បរិយាកាសអាជីវកម្មនៃឧស្សាហកម្មនេះ។ បច្ចុប្បន្ន សមាគមមានរោងចក្រកាត់ដេរសម្លៀកបំពាក់សមាជិកចំនួន៥១០រោងចក្រ និងរោងចក្រស្បែកជើងសមាជិកចំនួន៥៩ ដែលបានផ្តល់ការងារដល់កម្មករនិយោជិតប្រមាណ៧០០.០០០នាក់។

អំពីក្រុមហ៊ុន FUNAN Consulting Co., Ltd៖

ក្រុមហ៊ុន FUNAN Consulting Co., Ltd ជាក្រុមហ៊ុនជំនាញគណនេយ្យនិងសវនកម្មឯករាជ្យមួយដែលផ្តល់សវនកម្មនិងការជានាដែលអាចជឿទុកចិត្តបានលើផ្នែកគណនេយ្យ ពន្ធដារ ការគ្រប់គ្រងហិរញ្ញវត្ថុ ការប្រឹក្សាយោបល់អាជីវកម្ម ការផ្តល់យោបល់អំពី IT ការប្រឹក្សាយោបល់អំពីធនធានមនុស្ស សេវាបណ្តុះបណ្តាលទៅតាមតម្រូវការ និងជាក្រុមហ៊ុនផ្តល់សេវាវិជ្ជាជីវៈប្រឹក្សាយោបល់អាជីវកម្មដោយរួមចំណែកដល់ការអភិវឌ្ឍសកម្មភាពសេដ្ឋកិច្ចតាមរយៈសេវារបស់យើង និងតម្លៃរបស់យើង។ ដោយប្រើឧបករណ៍សវនកម្មរឹងមាំ ធនធាន និងបច្ចេកវិទ្យា ក្រុមអ្នកជំនាញវិជ្ជាជីវៈរបស់យើងធ្វើការយ៉ាងជិតស្និទ្ធជាមួយអតិថិជនដើម្បីផ្តល់សេវានិងដំណោះស្រាយប្រកបដោយគុណភាពខ្ពស់។

GARMENT MANUFACTURERS ASSOCIATION IN CAMBODIA